អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២

# សេចក្តីប្រកាសព័ត៌មាន

## លោក មុំ លុជ្ស ត្រូវបានតែងតាំងជាមេធាវីជាតិការពារក្តី

អង្គភាពគាំពារការពារក្តី នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានតែងតាំង លោក មុំ លុជ្ស (Mom Luch) ជាមេធាវីជាតិតំណាងជនសង្ស័យមួយរូបដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានផ្ញើជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី គឺជាផ្នែកមួយនៃសំណុំរឿង ០០៤។ លោក មុំ លុជ្ស មានបទពិសោធន៍ជាមេធាវីរយៈពេល ១៧ ឆ្នាំមកហើយ ដោយបំពេញការងារជាចម្បងនៅក្នុងវិស័យច្បាប់ព្រហ្មទណ្ឌ។ អត្តសញ្ញាណរបស់ជនសង្ស័យដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ត្រូវស្ថិតនៅជាសម្ងាត់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត៖ +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរស័ព្ទ៖ +៨៥៥(0) ២៣ ២១៩ ៨១៤ លេខបន្ត៖ ៦១៦៩
សារអេឡិចត្រូនិក៖ olsenl@un.org

**លោក នេត្រ ភក្ត្រា**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ៖ +៨៨៥(0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh